# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ក្រោមប្រធានបទ៖ ពាក្យខ្មែរថា «ការពារមុនប្រសើរជាងការព្យាបាល» និងពាក្យថា «ប្រហែសបាត់ប្រយ័ត្នគង់» ។

**Website: www.hoksavann.org**

ថ្ងៃទី២ កក្កដា ២០១០



ពាក្យថា «ការពារមុនប្រសើរជាងការព្យាបាល» គឺការពារកុំឲ្យកើតមានជម្ងឺ ដោយត្រូវមានអនាម័យវិធីការពារកុំឲ្យកើតរោគ ប្រសើរជាងមានរោគហើយទើបព្យាបាល ។ ប្រៀបដូចប្រទេសមួយ បើអ្នកដឹកនាំនិងប្រជាពលរដ្ឋព្រួតដៃគ្នាថែរក្សាការពារឯករាជ្យ អធិបតេយ្យជាតិ និងបូរណភាពទឹកដីរបស់ខ្លួនឲ្យបានគង់វង់ ប្រសើរជាងបាត់បង់ហើយទើបនាំគ្នាតស៊ូដណ្ដើមយកមកវិញ ។ ការបានដល់ដៃគេហើយទើបទាមទារមកវិញ ជាការពិបាកក្រៃលែង ហើយពុំងាយនឹងបានវិលត្រឡប់មកវិញតាមបំណងរបស់ខ្លួនផង ។ បើមធ្យោបាយទាមទារតាមផ្លូវច្បាប់បានសំរេចដូចបំណងនោះជាការប្រសើរ ។ ប៉ុន្តែបើការទាមទារដោយសន្តិវិធីតាមផ្លូវច្បាប់ពុំបានសំរេចដូចបំណងទេ ត្រូវប្រើយុទ្ធវិធី ត្រូវចំណាយជីវិតប្រជាពលរដ្ឋ ខូចខាតទ្រព្យសម្បត្តិរបស់ជាតិ ហើយខាតពេលវេលាក្នុងការអភិវឌ្ឍន៍ប្រទេសផង ។ ចំពោះប្រទេសកម្ពុជាបានបញ្ចប់សង្គ្រាមរួបរួមគ្នាឡើងវិញ តាមកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីសថ្ងៃទី២៣ តុលា ១៩៩១ ។ របបនយោបាយសេរីពហុបក្ស ទីផ្សារសេរី តម្រូវឲ្យថែរក្សាឯករាជ្យ អធិបតេយ្យជាតិ និងបូរណភាពទឹកដី ។ បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាព ទើបមានការបោះឆ្នោតឆ្នាំ១៩៩៣ តើខ្មែរមានឯករាជភាពពេញបរិបូណ៌ឬទេ ? តាមគេប្រាប់ថា សព្វថ្ងៃនេះវៀតណាមនៅតែបង្កប់ខ្លួននៅក្នុងជួររាជរដ្ឋាភិបាលខ្មែរ បញ្ជាសម្ងាត់នៅក្នុងក្រសួងសំខាន់ៗខ្លះ ។ គេប្រាប់ឈ្មោះក្រសួងនោះផង ប៉ុន្តែសូមមិនជឿតាមពាក្យគេថាទេ សូមសួរទៅរាជរដ្ឋាភិបាលឲ្យឆ្លើយប្រាប់ប្រជាពលរដ្ឋវិញថា តើមានវៀតណាមបង្កប់ខ្លួន នៅបញ្ជាលើរាជរដ្ឋាភិបាលចំពោះកិច្ចការសំខាន់ៗរបស់ជាតិឬទេ ? ហេតុអ្វីបានជាក្រសួងមហាផ្ទៃមិនព្រមឆ្លើយប្រាប់ប្រជាពលរដ្ឋខ្មែរឲ្យត្រង់ថា វៀតណាមចូលមកប្រទេសកម្ពុជាដោយខុសច្បាប់មានប៉ុន្មាននាក់ ? ហេតុអ្វីបានជារាជរដ្ឋាភិបាលខ្មែរមិនព្រមធ្វើសហការជាមួយគណបក្សប្រឆាំង សង្គមស៊ីវិល និងប្រជាពលរដ្ឋក្នុងការវាស់ព្រំប្រទល់ដែនកម្ពុជា-វៀតណាម ? ហេតុអ្វីបានជាចាប់ពលរដ្ឋដាក់ពន្ធនាគារ ដោយលោកគ្រាន់តែបញ្ចេញមតិដើម្បីការពារដីស្រែរបស់ខ្លួន ? ហេតុអ្វីបានជាមិនជួយសំរួលដល់បងប្អូនខ្មែរកម្ពុជាក្រោម ដែលរត់ចូលមកប្រទេសកម្ពុជាពីវៀតណាមធ្វើបាបឲ្យមានសញ្ជាតិត្រឹមត្រូវ ? លើកយកភស្តុតាងខ្លះប៉ុណ្ណោះ ជាវិញ្ញាសារសំរាប់ពិចារណាថា តើវៀតណាមនៅតែមានឥទ្ធិពលលើរាជរដ្ឋាភិបាលខ្មែរឬ ? ការការពារឯករាជ្យ អធិបតេយ្យជាតិ និងបូរណាភាពទឹកដី គ្មានអ្វីក្រៅពីអ្នកកាន់អំណាចគ្រប់ស្ថាប័នរួបរួមជាមួយប្រជាពលរដ្ឋ ព្រួតដៃគ្នារក្សាការពារឲ្យបានម៉ឺងម៉ាត់ដោយការប្រុងប្រយ័ត្ន ទើបស្ថាប័នរបស់ជាតិទាំងនោះគង់វង់ ។

ពាក្យថា «ប្រហែសបាត់ប្រយ័ត្នគង់» ក៏មានន័យស្រដៀងគ្នានឹងពាក្យខាងដើមថា «ការពារមុនប្រសើរជាងការព្យាបាល» ជាពាក្យមានន័យថា របស់អ្វីក៏ដោយបើមិនថែរក្សាទេ របស់នោះតែងខូចខាតនិងបាត់បង់ ។ បើបានរក្សាហ្មត់ចត់មិនធ្វេសប្រហែស ទើបរបស់គ្រប់យ៉ាងនឹងស្ថិតនៅគង់វង់ ។ គេតែងពោលថា ការទាមទារយកឯករាជ្យ យកសិទ្ធិសេរីភាព យកទឹកដីដែលបានបាត់បង់ជាការពិបាកមួយហើយ ប៉ុន្តែពិបាកជាងនេះទៅទៀត គឺនៅត្រង់រក្សារបស់ទាំងនោះឲ្យបានគង់វង់ ។ ដូចប្រទេសកម្ពុជានៅសម័យមហានគរ មានទឹកដីធំទូលំទូលាយ មានវប្បធម៌ចំរើនរុងរឿង លុះសម័យក្រោយមកទឹកដីបាននៅរួមតូចដូចសព្វថ្ងៃនេះ ។ កត្តាដែលនាំឲ្យចុះខ្សោយ គឺបណ្ដាលមកពីសម័យនោះ ច្បាប់ទម្លាប់អន្តរជាតិមិនទាន់មានបរិបូណ៌ដូចច្បាប់អង្គការសហប្រជាជាតិសព្វថ្ងៃនេះទេ ម៉្លោះហើយប្រទេសណាមានកម្លាំងទ័ពខ្លាំង ដូចខ្មែរយើងនិយាយថា កម្លាំងបាយខ្លាំង តែងឈ្នះប្រទេសដែលមានកម្លាំងទ័ពខ្សោយ ហើយគ្មានច្បាប់អន្តរជាតិជួយការពារប្រទេសទន់ខ្សោយ ផ្ដន្ទាទោសប្រទេសឈ្លានពានគេឡើយ ព្រោះធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ទើបនឹងកើតមាននៅថ្ងៃ១០ធ្នូ១៩៤៨នេះទេ ។ មួយទៀតបញ្ហាដែលរាជាណាចក្រកម្ពុជាបានត្រូវចុះខ្សោយ គឺដោយមានបញ្ហាផ្ទៃក្នុងរបស់ខ្លួនបែកបាក់សាមគ្គីគ្នា ព្រោះការដណ្ដើមអំណាចគ្នា ជាឱកាសល្អរបស់ប្រទេសទាំងពីរ គឺប្រទេសវៀតណាមនិងប្រទេសថៃ បានចូលមកឈ្លានពានប្រទេសកម្ពុជា តាមរយៈការបែកបាក់គ្នារបស់ខ្មែរនេះឯង ។ រហូតមកទល់ថ្ងៃនេះ ប្រទេសទាំងពីរនេះនៅតែមានមហិច្ឆិតាចង់បានដីគោកដីសមុទ្រខ្មែរជាបន្តទៅទៀត ។ ដូច្នេះតម្រូវឲ្យខ្មែរបណ្ដុះគំនិតជាតិនិយមឲ្យខ្លាំងឡើងថែមទៀត រក្សាកេរមត៌កខ្មែរដែលសេសសល់តិចតួចនេះឲ្យគង់វង់ ។ ដើម្បីរក្សាកេរមត៌កជាតិឲ្យគង់វង់ អទិភាពទីមួយ គឺសាមគ្គីគ្នាមិនត្រូវបែកបាក់គ្នាចំពោះមុខសត្រូវឈ្លានពាន ។ ដើម្បីសាមគ្គីគ្នាបាន គប្បីខ្មែរគ្រប់រូបលើកតម្លៃនិងប្រយោជន៍ជាតិឲ្យខ្ពស់ ត្រូវបំពេញកិច្ចការតាមមុខងាររៀងខ្លួន ជៀសវាងការបៀតបៀនគ្នាដែលនាំឲ្យខ្មែរបែកបាក់ ពុំមានឯកភាពជាតិ ។៚

❄ ❄

❄